Legal Services **COMMISSIONER**

*Working with your lawyer - Khmer*

# ការធ្វើកិច្ចការជាមួយមេធាវីលោកអ្នក

**ខាងក្រោមនេះគឺជាចំណុចសំខាន់ៗដែលប្រហែលជាជួយលោកអ្នកបង្កើតនិងរក្សាទំនាក់ទំនងវិជ្ជមានមួយជាមួយមេធាវីរបស់លោកអ្នក**

## មុនជំនួបទីមួយ

- សូមឆែកមើលតម្លៃនៃការសំយោបល់ដំបូងហើយនឹងប្រើពេលប៉ុន្មានដែរ។
- សូមឆែកមើលថាតើមេធាវីនេះមានបទពិសោធន៍ឬធ្វើឯកទេសកម្មខាងផ្នែករឿងច្បាប់របស់លោកអ្នកទេ។
- សូមកត់ត្រាទុកនូវភាពលំអិតនៃបញ្ហាច្បាប់: អ្វីបានកើតឡើង, ពេលណាដែលវាបានកើតឡើងហើយនិងនរណានៅទីនោះ។
- សូមចម្លងទុកឯកសារទាំងឡាយណាដែលប្រហែលជាមានពាក់ព័ន្ធនឹងរឿងច្បាប់របស់លោកអ្នក។
- សូមសរសេរសំនួរទាំងឡាយដែលលោកអ្នកចង់សាកសួរមេធាវីនេះ។
- សូមសរសេរលទ្ធផលដែលលោកអ្នកសង្ឃឹមថាបានសម្រេចក្នុងរឿងរបស់លោកអ្នក។
- ប្រសិនបើលោកអ្នកមានអារម្មណ៍ថាវានឹងមានប្រយោជន៍, សូមរៀបចំឲ្យមានមិត្តភក្តិ, ញាតិសន្តាន ឬអ្នកគាំទ្រទៅជាមួយលោកអ្នកនៅជំនួបទីមួយនេះ។
- សូមរៀបចំឲ្យគេរកអ្នកបកប្រែភាសាជូន, ប្រសិនបើលោកអ្នកត្រូវការ។

## នៅជំនួបទីមួយ

- សូមសាកសួរអំពីតម្លៃ(ឬជំនួយខាងច្បាប់ប្រសិនបើលោកអ្នកត្រូវការជំនួយប្រាក់កាស)។
- សូមកត់ត្រាកំណត់ហេតុអ្វីៗដែលត្រូវបានគេនិយាយប្រាប់លោកអ្នក។
- សូមផ្តល់ជូនមេធាវីនេះនូវច្បាប់ចម្លងនៃកំណត់ហេតុដែលលោកអ្នកបានរៀបចំនិងឯកសារនានាដែលលោកអ្នកបានថតចម្លង។
- សូមឆ្លើយដោយច្បាស់លាស់នូវសំនួរដែលមេធាវីលោកអ្នកសួរលោកអ្នក។
- សូមសាកសួរមេធាវីនូវសំនួរនានាដែលលោកអ្នកពុំយល់អ្វីៗនោះ ឬចង់ដឹងអំពីអ្វីដែលលោកអ្នកត្រូវការធ្វើ។
- សូមសាកសួរមេធាវីនូវនិយមន័យនៃពាក្យច្បាប់ណាមួយដែលលោកអ្នកពុំយល់។
- សូមសាកសួរមេធាវីនូវជំរើសអ្វីខ្លះដែលមានដើម្បីដោះស្រាយរឿងច្បាប់របស់លោកអ្នក។
- សូមប្រាប់មេធាវីនូវកង្វល់ណាមួយដែលលោកអ្នកមានស្តីអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោកអ្នក។
- សូមសាកសួរមេធាវីនូវអ្វីដែលនឹងកើតឡើងបន្ទាប់មក ហើយវាប្រើពេលប៉ុន្មានទៅដើម្បីដោះស្រាយរឿងច្បាប់របស់លោកអ្នក។

## ការពិនិត្យពិច័យតទៅទៀត

- សូមកត់ត្រាកំណត់ហេតុអ្វីៗដែលមេធាវីលោកអ្នកប្រាប់លោកអ្នក។
- សូមរក្សាទុកកំណត់ហេតុទាំងនេះហើយនិងសំបុត្រនិងឯកសារទាំងអស់ដែលត្រូវបានផ្ញើមកជូនលោកអ្នកដោយមេធាវីលោកអ្នកនោះជាមួយនិងសំណុំរឿងឬក្រុបសំណុំរឿង។
- សូមប្រាប់មេធាវីប្រសិនបើព័ត៌មានលំអិតផ្ទាល់ខ្លួនរបស់លោកអ្នកផ្លាស់ប្តូរ។
- សូមសាកសួរមេធាវីនូវសំនួរប្រសិនបើលោកអ្នកមិនយល់នូវអ្វីដែលបានកើតឡើងឬអ្វីនឹងកើតឡើងបន្ទាប់មកទៀត។
- ប្រសិនបើបញ្ហាច្បាប់នេះជាប់ទាក់ទិននឹងការឡើងតុលាការ សូមសាកសួរមេធាវីថាតើការយល់ព្រម "ផ្សះផ្សា" រឿងច្បាប់លោកអ្នកមានន័យដូចម្តេចដែរជាជាងឡើងទៅតុលាការ(រួមទាំងតម្លៃច្បាប់នេះអស់ប៉ុន្មាន)។
- សូមសាកសួរមេធាវីថាតើតម្លៃនឹងប្រហែលជាឡើងថែមទៀតតាំងពីការប៉ាន់ស្មានតម្លៃដំបូង។

## ប្រសិនបើលោកអ្នកមានបញ្ហាជាមួយមេធាវីរបស់លោកអ្នក

- សូមលើកយកកង្វល់របស់លោកអ្នកពិភាក្សាផ្ទាល់ជាមួយមេធាវីលោកអ្នក ឬដៃគូគ្រប់គ្រងរបស់មេធាវីលោកអ្នក។
- ផ្លាស់ប្តូរមេធាវី(យ៉ាងណាក៏ដោយ, សូមកត់សំគាល់ថាមេធាវីនេះអាចរក្សាទុកសំណុំរឿងរបស់លោកអ្នករហូតដល់តម្លៃច្បាប់ត្រូវបានបង់ឲ្យអស់)។
- ប្រសិនបើលោកអ្នកពុំអាចដោះស្រាយរឿងនេះទេ, សូមទាក់ទងស្នងការកិច្ចបំរើខាងច្បាប់, គឺជាផ្លូវមួយគត់របស់រដ្ឋវិចតូរិយ៉ាសំរាប់ការដោះស្រាយត្រឹមត្រូវ, ឯករាជនិងមានប្រសិទ្ធិភាពលើការប្តឹងផ្តល់មេធាវី។

## ព័ត៌មានថែមទៀត?


Legal Services Commissioner
5/555 Bourke Street
Melbourne VIC 3000

ទូរស័ព្ទ: 1300 796 344 (ទូរស័ព្ទតំបន់នៅក្នុងរដ្ឋវិចតូរិយ៉ា)
ទូរស័ព្ទ: 03 9679 8001
ទូរសារ: 03 9679 8101
អ៊ីមែល: admin@lsbc.vic.gov.au

www.lsbc.vic.gov.au


កិច្ចបំរើការបកប្រែភាសាអាចរកជូនបាន